# ជំពូកទី ៦

# ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

## ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន

**ប្រការ** ៦.១.-

ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជន សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋទាំងពីរភេទ ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

៦.១.១ មានសញ្ជាតិខ្មែរពីកំណើត ។

៦.១.២ ចេះអាន និងសរសេរអក្សរខ្មែរ ។

៦.១.៣ បានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត ។

៦.១.៤ មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន

**ប្រការ** ៦.២.-

ហាមឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះ ៖

៦.២.១ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមប្រឹក្សានៃអង្គចៅក្រម សមាជិករាជរដ្ឋាភិបាល និងចៅក្រម ។

៦.២.២ អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

៦.២.៣ សមាជិក គ.ជ.ប គធ.ខប គឃ.សប គ.ក.ប បុគ្គលិកបម្រើការងារក្នុង គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

៦.២.៤ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង ។

៦.២.៥ ព្រះសង្ឃ ឬបព្វជិតសាសនានៃសាសនាណាមួយ ។

៦.២.៦ ស្មៀនឃុំ សង្កាត់ណាមួយ ។

**ប្រការ** ៦.៣.-

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិច ០៧ (ប្រាំពីរ)ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។

៦.៣.១ ប្រសិនបើ សាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅសាមីក្រសួង ឬសាមីអង្គភាពទៅបម្រើការក្រៅក្របខ័ណ្ឌដើមក្នុងរយៈពេលអាណត្តិរបស់ខ្លួន ។ ក្នុងឋានៈ នេះសាមីខ្លួនត្រូវមានសិទ្ធិឡើងថ្នាក់ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ ។

៦.៣.២ នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សាមីខ្លួនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច ។

៦.៣.៣ លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ឬអង្គភាព អាចភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។ ក្នុងករណីមិនអាចធ្វើទាន់ ត្រូវធ្វើពាក្យសុំច្បាប់ឈប់ពិសេសជូន គឃ.សប ក្នុងរយៈពេលយ៉ាងតិច ០៧ (ប្រាំពីរ)ថ្ងៃ មុនថ្ងៃចាប់ផ្ដើមបើកយុទ្ធនាការឃោសនាបោះឆ្នោត ។ លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីឈ្មោះសាមីជន ដែលបានសុំច្បាប់ឈប់ពិសេស មុខតំណែង ក្រសួង ឬអង្គភាព ដែលសាមីជនកំពុងបម្រើការងារកាលបរិច្ឆេទ សុំច្បាប់ឈប់ពិសេស និងមានហត្ថលេខារបស់ថ្នាក់ដឹកនាំរបស់ខ្លួន ពោលគឺនៅថ្នាក់លើមួយថ្នាក់ដែលខ្លួននៅក្រោមឱវាទ ។

**ប្រការ** ៦.៤.-

បន្ទាប់ពីនាយករដ្ឋមន្ត្រីកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣ នៃ ច.ប.ឃ.ស គ.ជ.ប ត្រូវផ្សព្វផ្សាយនៅក្នុងឃុំ សង្កាត់នីមួយៗ នូវកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កាលបរិច្ឆេទនៃការចុះបញ្ជីបេក្ខជន និងទីកន្លែង ។

**ប្រការ** ៦.៥.-

ជនគ្រប់រូបដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយ ។

៦.៥.១ បញ្ជីបេក្ខជននីមួយៗ ត្រូវរៀបចំដោយគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌ ដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ។

៦.៥.២ បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង ។

៦.៥.៣ បេក្ខជនម្នាក់ៗ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយប៉ុណ្ណោះ ។ បេក្ខជនម្នាក់ៗ មិនត្រូវបានអនុញ្ញាតឱ្យលាឈប់ពីបេក្ខភាព មុនបញ្ជីបេក្ខជនផ្លូវការ ត្រូវបានសម្រេចឡើយ ។

**ប្រការ** ៦.៦.-

ដើម្បីឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត តាមការកំណត់របស់ គ.ជ.ប ទៅ គឃ.សប យ៉ាងតិច ៩០ (កៅសិប)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៦.៦.១ គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត តាម ទ.១០០៨ ចំនួន ០២(ពីរ)ច្បាប់ ។ ពាក្យសុំចុះបញ្ជីបេក្ខជននេះ ត្រូវបានផ្តល់ដោយឥតគិតថ្លៃ ជូនគណបក្សនយោបាយ ដែលមានបំណងចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។

៦.៦.២ ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាង ដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។ ការផ្ទេរសិទ្ធិនេះ មិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះមានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត ។

៦.៦.៣ ពាក្យសុំចុះបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយនូវ ៖

៦.៦.៣.១ សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ចំនួន ០១(មួយ)ច្បាប់ ។

៦.៦.៣.២ អាសយដ្ឋាននៃទីស្នាក់ការកណ្តាលគណបក្សនយោបាយ អាសយដ្ឋានទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ និងឈ្មោះតំណាងប្រចាំទីស្នាក់ការគណបក្សនយោបាយក្នុងឃុំ សង្កាត់ ដែលបានដាក់ស្នើបញ្ជីបេក្ខជន ។

៦.៦.៣.៣ បញ្ជីរាយនាមបេក្ខជនចំនួន ០៧(ប្រាំពីរ) ច្បាប់ ដែលមានចំនួនបេក្ខជនយ៉ាងហោចណាស់ស្មើនឹងពីរដង នៃចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។ គឃ.សប ត្រូវរក្សាឱ្យបានបញ្ជីរាយនាមបេក្ខជនទាំង ០៧ (ប្រាំពីរ) ច្បាប់ ដើម្បីប្រើប្រាស់ ៖

- ០១ (មួយ) ច្បាប់ បិទផ្សាយនៅទីស្នាក់ការ គឃ.សប ក្រោយពេលទទួលពាក្យសុំចុះបញ្ជីបេក្ខជន
- ០១ (មួយ)ច្បាប់ បិទផ្សាយនៅ គឃ.សប ជាបញ្ជីបេក្ខជនដំបូង
- ០១ (មួយ) ច្បាប់ បិទផ្សាយនៅ គឃ.សប ជាបញ្ជីបេក្ខជនផ្លូវការ
- ០១ (មួយ) ច្បាប់ តម្កល់ទុកជាឯកសារនៅ គឃ.សប
- ០១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប
- ០១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប
- ០១ (មួយ) ច្បាប់ ជូនសាមីគណបក្សនយោបាយ

៦.៦.៣.៤ លិខិតបញ្ជាក់ពីមេឃុំ ចៅសង្កាត់ថា ពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោតដោយបញ្ជាក់ឱ្យបានច្បាស់ អំពីនាមត្រកូល នាមខ្លួន និងអាសយដ្ឋាន ។ មេឃុំ ចៅសង្កាត់ ត្រូវចេញលិខិតបញ្ជាក់ជូនតាមការស្នើសុំក្នុងរយៈពេលយ៉ាងយូរ ០៣(បី)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំ ដោយផ្អែកលើបញ្ជីបោះឆ្នោតផ្លូវការ ។

៦.៦.៣.៥ ជីវប្រវត្តិសង្ខេប និងសេចក្តីប្រកាសយល់ព្រមឈរឈ្មោះរបស់បេក្ខជនដែលបំពេញផ្ទាល់ដៃរបស់បេក្ខជនម្នាក់ៗ មានបិទរូបថត និងរូបថតបេក្ខជនម្នាក់ចំនួន ០៣ (បី)សន្លឹកទៀត ទំហំ ៤x៦ ថតចំពីមុខ តាមគំរូរូបថតធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។ ការប្រើប្រាស់រូបថតរបស់បេក្ខជននៃគណបក្សនយោបាយនីមួយៗ ៖

- ០១ (មួយ) សន្លឹក សម្រាប់បិទផ្សាយជាមួយបញ្ជីបេក្ខជនបន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនរួច នៅទីស្នាក់ការ គឃ.សប
- ០១ (មួយ) សន្លឹក សម្រាប់បិទជាបញ្ជីបេក្ខជនដំបូងនៅទីស្នាក់ការ គឃ.សប
- ០១ (មួយ) សន្លឹក សម្រាប់បិទផ្សាយបញ្ជីបេក្ខជនផ្លូវការនៅទីស្នាក់ការ គឃ.សប ។

របៀបបិទរូបថតបេក្ខជន ៖ គឃ.សប ត្រូវបិទរូបថតតាមលេខរៀងឈ្មោះបេក្ខជននៃគណបក្សនយោបាយនីមួយៗលើក្រដាសដែលមានទំហំសមស្របទៅតាមចំនួនបេក្ខជន ។

៦.៦.៣.៦ លិខិតសន្យារបស់បេក្ខជនឈរឈ្មោះបោះឆ្នោតដែលជាមន្ត្រីរាជការថានឹងផ្តល់ច្បាប់សុំឈប់ពិសេសជូន គឃ.សប ។

៦.៦.៣.៧ ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និង សញ្ញាសម្គាល់គណបក្សនយោបាយ ។

**ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនដោយ គឃ.សប**

**ប្រការ** ៦.៧.–

គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជនសម្រាប់ឃុំ សង្កាត់ នីមួយៗ ។

៦.៧.១ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីបេក្ខជននៅគ្រប់ទីស្នាក់ការ គឃ.សប ។

៦.៧.២ ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនមានរយៈពេល ០៣ (បី)ថ្ងៃ គឺរៀងរាល់ថ្ងៃ ព្រឹកចាប់ពីម៉ោង ៧:០០នាទី ដល់ ១១:៣០នាទី រសៀលចាប់ពីម៉ោង ២:០០នាទី ដល់ ៥:៣០នាទី ។

៦.៧.៣ គឃ.សប ត្រូវចេញបង្កាន់ដៃទទួលពាក្យជូនគណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីបេក្ខជន និងរក្សាគល់បញ្ជី ០១ (មួយ)ច្បាប់ ទុកជាឯកសារ ។

៦.៧.៤ បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួន និងប្រភេទឯកសារដែលបានទទួល ចុះកាលបរិច្ឆេទប្រគល់ ទទួល និងហត្ថលេខា ឬស្នាមមេដៃនៃអ្នកប្រគល់ទទួល ។

៦.៧.៥ នៅពេលបញ្ចប់ការទទួលពាក្យ គឃ.សប ត្រូវធ្វើកំណត់ហេតុស្តីពីលទ្ធផលនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សម្រាប់ឃុំ សង្កាត់របស់ខ្លួនចំនួន ០៤ (បួន)ច្បាប់ ដោយមានចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រា គឃ.សប រួចបិទផ្សាយ ០១ (មួយ)ច្បាប់ នៅទីស្នាក់ការ គឃ.សប ផ្ញើជូន គធ.ខប ០១ (មួយ)ច្បាប់ ជូន គ.ជ.ប ០១ (មួយ)ច្បាប់ និងរក្សាទុកជាឯកសារ ០១ (មួយ)ច្បាប់ ។ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាលើកំណត់ហេតុនេះបាន ។

**ប្រការ** ៦.៨.-

បន្ទាប់ពីថ្ងៃបញ្ចប់ការទទួលពាក្យសុំចុះបញ្ជីបេក្ខជន គឃ.សប ត្រូវធ្វើការពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនទាំងនោះក្នុងរយៈពេល ០១ (មួយ) ថ្ងៃ ។ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួន នូវបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានទទួលពាក្យសុំចុះបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជន ។

**ប្រការ** ៦.៩.-

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់មានសិទ្ធិផ្តល់មតិចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានបិទផ្សាយខាងលើ មក គឃ.សប ដើម្បីជាព័ត៌មានសម្រាប់ជាមូលដ្ឋានពិចារណាមុនពេលសម្រេចយល់ព្រម ឬបដិសេធការសុំចុះបញ្ជីបេក្ខជន។

**ការពិនិត្យ និងសម្រេចរបស់ គឃ.សប លើពាក្យសុំចុះបញ្ជីបេក្ខជន**

**ប្រការ** ៦.១០.-

គឃ.សប ត្រូវពិនិត្យ និងសម្រេចយល់ព្រម ឬបដិសេធលើពាក្យសុំចុះបញ្ជីបេក្ខជនរបស់គណបក្សនយោបាយតាមលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងប្រការ ៦.១ ៦.២ ៦.៣ ៦.៥ ៦.៦ នៃ ប.ន.យ.ស នេះ ក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំចុះបញ្ជីបេក្ខជន ។

៦.១០.១ ក្នុងករណីគណបក្សនយោបាយណាមួយ បានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើ គឃ.សប ត្រូវសម្រេចយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជននោះ ដោយត្រូវបំពេញលើពាក្យសុំចុះបញ្ជីបេក្ខជន (ទ.១០០៨) ទាំង ០២ (ពីរ) ច្បាប់ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា រួចជូនទៅសាមីគណបក្សនយោបាយ ០១ (មួយ)ច្បាប់ និងរក្សាទុក ០១ (មួយ)ច្បាប់ ។

៦.១០.១.១ ករណីឃុំ សង្កាត់ណាមួយត្រូវបាន គឃ.សប សម្រេចយល់ ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជនរបស់គណបក្សនយោបាយ ដែលបាន

ស្នើសុំទាំងអស់ក្នុងឃុំ សង្កាត់នោះ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួន នូវបញ្ជីបេក្ខជនដំបូងក្នុងរយៈពេលយ៉ាងយូរ ០៣(បី) ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចយល់ព្រម ។

៦.១០.១.២ ប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ ។ នីតិវិធីនៃការប្តឹងជំទាស់នឹងបេក្ខជន ឬបញ្ជីបេក្ខជនដំបូងត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៦.១៥ ។

៦.១០.១.៣ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៦.១០.១.២ បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងទេនោះ ចាត់ទុកថាគ្មានការប្តឹងជំទាស់ ។ បញ្ជីបេក្ខជនដំបូង ក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ ។ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជននីមួយៗក្នុងរយៈពេលយ៉ាងយូរ ០៧(ប្រាំពីរ)ថ្ងៃ ។

៦.១០.១.៤ គឃ.សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ គធ.ខប ។ ការចាប់ឆ្នោតកំណត់លេខរៀង គឃ.សប ត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៦.២០ ។

៦.១០.២ ក្នុងករណីគណបក្សនយោបាយណាមួយ បំពេញមិនបានត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើ គឃ.សប ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងណែនាំដល់គណបក្សនយោបាយ ដែលបានដាក់ស្នើបញ្ជីបេក្ខជននោះឱ្យធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវ ហើយផ្តល់ឱកាសឱ្យគណបក្សនយោបាយនោះ ធ្វើការកែតម្រូវចំណុចខ្វះខាតក្នុងរយៈពេលយ៉ាងយូរ ០៥(ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ។

៦.១០.៣ ក្នុងករណីគណបក្សនយោបាយ ដែលបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរពី គឃ.សប ឱ្យធ្វើការកែតម្រូវនូវចំណុចខ្វះខាត បានកែតម្រូវត្រឹមត្រូវ និងទាន់ពេលវេលាហើយនោះ គឃ.សប ត្រូវយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជនដូចក្នុងចំណុច ៦.១០.១ ក្នុងរយៈពេល ០១ (មួយ) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំដែលបានកែតម្រូវរួចហើយ ។

៦.១០.៣.១ ក្នុងករណីគណបក្សនយោបាយទាំងអស់ដែល គឃ.សប ឱ្យធ្វើការកែតម្រូវនូវចំណុចខ្វះខាត បានកែតម្រូវត្រឹមត្រូវ ហើយត្រូវបាន គឃ.សប សម្រេចដូចចំណុច ៦.១០.៣ ខាងលើ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈ នៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃសម្រេចយល់ព្រម ។

៦.១០.៣.២ ប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ ។ នីតិវិធីនៃការប្តឹងជំទាស់ នឹងបេក្ខជន ឬបញ្ជីបេក្ខជនដំបូងត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៦.១៥ ។

៦.១០.៣.៣ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៦.១០.៣.២ បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងទេនោះ ចាត់ទុកថាគ្មានការប្តឹងជំទាស់ ។ បញ្ជីបេក្ខជនដំបូងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ ។ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈ នៅទីស្នាក់ការរបស់ខ្លួន នូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជននីមួយៗក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ ។

៦.១០.៣.៤ គឃ.សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជន ដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះ ទៅ គ.ជ.ប តាមរយៈ គធ.ខប ។ ការចាប់ឆ្នោតកំណត់លេខរៀង គឃ.សប ត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៦.២០ ។

៦.១០.៤ ក្នុងករណីគណបក្សនយោបាយដែលដាក់ស្នើបញ្ជីបេក្ខជន មិនបានកែតម្រូវចំណុចខ្វះខាតតាមលក្ខខណ្ឌ និងពេលវេលាដូចមានចែងក្នុងប្រការ ៦.១០ និងចំណុច ៦.១០.២ ខាងលើ គឃ.សប ត្រូវបដិសេធពាក្យសុំចុះបញ្ជីបេក្ខជននោះ ។

៦.១០.៥ ក្នុងការសម្រេចបដិសេធ គឃ.សប ត្រូវ ៖

៦.១០.៥.១ បំពេញ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសម្រង់សេចក្តីសម្រេចបដិសេធ (ទ.១២០៣) ចំនួន ០៣ (បី) ច្បាប់ រួចផ្ញើជូន ៖

- សាមីគណបក្សនយោបាយ ឬតំណាង ០១ (មួយ)ច្បាប់
- គធ.ខប ០១ (មួយ)ច្បាប់
- រក្សាទុកឯកសារ ០១ (មួយ)ច្បាប់។

៦.១០.៥.២ ប្រគល់ទម្រង់បែបបទលេខ ១២០២ ចំនួន ០៣ (បី) ច្បាប់ ជូនដល់សាមីគណបក្សនយោបាយ ឬតំណាង ដែលបានដាក់ស្នើបញ្ជីបេក្ខជន សម្រាប់បំពេញពាក្យបណ្ដឹងតវ៉ាទៅ គធ.ខប ។

**ប្រការ** ៦.១១.-

គណបក្សនយោបាយណាដែលបានដាក់ស្នើបញ្ជីបេក្ខជន ហើយត្រូវបាន គឃ.សប បដិសេធ សាមីគណបក្ស ឬតំណាងមានសិទ្ធិប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទបដិសេធ ។

៦.១១.១ បន្ទាប់ពីបានទទួលសម្រង់សេចក្ដីសម្រេចបដិសេធ ប៉ុន្តែសាមីគណបក្ស ឬតំណាងពុំបានដាក់ពាក្យប្ដឹងតវ៉ាទៅ គធ.ខប តាមពេលវេលាដូចចែងក្នុងប្រការ ៦.១១ ទេនោះ ត្រូវចាត់ទុកថាមិនបានប្ដឹងតវ៉ា ។

៦.១១.២ ក្នុងករណីមានបណ្ដឹងតវ៉ា គធ.ខប ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ០៣(បី) ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្ដឹងតវ៉ាពីសាមីគណបក្ស ឬតំណាង។ គធ.ខប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលត្រូវបើកសវនាការ ។

៦.១១.៣ ក្នុងករណីសម្រេចយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា គធ.ខប ត្រូវបំពេញសម្រង់សេចក្ដីសម្រេចលើបណ្ដឹងតវ៉ា (ទ.១២០៣) ជា ០៤(បួន) ច្បាប់ ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ រួចផ្ញើជូន ៖

- អ្នកប្ដឹងតវ៉ា ០១ (មួយ) ច្បាប់
- គឃ.សប ០១ (មួយ) ច្បាប់
- គ.ជ.ប ដើម្បីជ្រាបជាព័ត៌មាន ០១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ០១ (មួយ) ច្បាប់ ។

៦.១១.៤ ក្នុងករណីទទួលបានសម្រង់សេចក្តីសម្រេចយល់ព្រមដូចក្នុងចំណុច ៦.១១.៣ គឃ.សប ត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយនោះ និង ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនជូនសាមីគណបក្សនយោបាយ ដោយត្រូវ បំពេញលើពាក្យសុំចុះបញ្ជីបេក្ខជន (ទ.១០០៨) ទាំង ០២ (ពីរ) ច្បាប់ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា រួចជូនទៅសាមីគណបក្សនយោបាយ ០១ (មួយ)ច្បាប់ និងរក្សាទុក ០១ (មួយ)ច្បាប់ ។

៦.១១.៤.១ ករណីបណ្តឹងតវ៉ាទាំងអស់ក្នុងឃុំ សង្កាត់នោះ ត្រូវបានយល់ព្រម ដោយ គធ.ខប គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការ របស់ខ្លួននូវបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ០៣(បី) ថ្ងៃ បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេចពី គធ.ខប ។

៦.១១.៤.២ ប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ មាន សិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន ឬ បញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃ បិទផ្សាយជាសាធារណៈ ។ នីតិវិធីនៃការប្តឹងជំទាស់នឹងបេក្ខជន ឬ បញ្ជីបេក្ខជនដំបូងត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៦.១៥ ។

៦.១១.៤.៣ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៦.១១.៤.២ បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងទេ នោះ ចាត់ទុកថាគ្មានការប្តឹងជំទាស់ ។ បញ្ជីបេក្ខជនដំបូងក្លាយទៅជា បញ្ជីបេក្ខជនផ្លូវការ ។ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅ ទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជននីមួយៗ ក្នុងរយៈពេលយ៉ាងយូរ ០៧(ប្រាំពីរ) ថ្ងៃ ។

៦.១១.៤.៤ គឃ.សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជី បេក្ខជន ដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះ ទៅ គ.ជ.ប តាមរយៈ គធ.ខប ។ ការចាប់ឆ្នោតកំណត់លេខរៀង គឃ.សប ត្រូវអនុវត្ត ដូចមានចែងក្រោមប្រការ ៦.២០ ។

**ប្រការ** ៦.១២.-

ក្នុងករណីសម្រេចបដិសេធលើបណ្តឹងតវ៉ា គធ.ខប ត្រូវបំពេញសម្រង់សេចក្តីសម្រេចលើបណ្តឹងតវ៉ា (ទ.១២០៣) ជា ០៤ (បួន) ច្បាប់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់រួចផ្ញើជូន ៖

- គណបក្សនយោបាយសាមី 01 (មួយ) ច្បាប់
- គ.ជ.ប 01 (មួយ) ច្បាប់
- គឃ.សប 01 (មួយ) ច្បាប់
- រក្សាទុកជាឯកសារ 01 (មួយ) ច្បាប់

គធ.ខប ត្រូវប្រគល់ ទ.១២០២ ចំនួន ០៣(បី) ច្បាប់ ជូនគណបក្សនយោបាយ សម្រាប់បំពេញពាក្យប្ដឹងតវ៉ាទៅ គ.ជ.ប ។

**ប្រការ** ៦.១៣.-

គណបក្សនយោបាយដែលបានដាក់ស្នើបញ្ជីបេក្ខជន ហើយបញ្ជីបេក្ខជននោះត្រូវបានបដិសេធដោយ គធ.ខប សាមីគណបក្សនយោបាយ ឬតំណាងមានសិទ្ធិប្ដឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលទម្រង់បែបបទបដិសេធ ។

៦.១៣.១ គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្រោយពីបានទទួលទម្រង់បែបបទប្ដឹងតវ៉ា ។

៦.១៣.២ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនៅទីស្ដីការរបស់ខ្លួននូវកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង ដែលត្រូវបើកសវនាការ ។

៦.១៣.៣ ក្នុងករណីយល់ព្រមលើការប្ដឹងតវ៉ា គ.ជ.ប ត្រូវ ៖

៦.១៣.៣.១ បំពេញសម្រង់សេចក្ដីសម្រេចលើបណ្ដឹងតវ៉ា (ទ.១២០៣) ជា ០៤ (បួន)ច្បាប់ រួចផ្ញើជូន ៖

- អ្នកប្ដឹងតវ៉ា 01 (មួយ) ច្បាប់
- គធ.ខប 01 (មួយ) ច្បាប់
- គឃ.សប 01 (មួយ) ច្បាប់
- រក្សាទុកជាឯកសារ 01 (មួយ) ច្បាប់ ។

៦.១៣.៣.២ បន្ទាប់ពីទទួលបានសម្រង់សេចក្ដីសម្រេចយល់ព្រម ដូចក្នុងចំណុច ៦.១៣.៣.១ រួចហើយ គឃ.សប ត្រូវផ្ដល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីបេក្ខជន និងត្រូវចុះបញ្ជីបេក្ខជន ជូនគណបក្សនយោបាយ ហើយចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជន ជូនគណបក្សនយោបាយសាមី ដោយត្រូវបំពេញលើពាក្យសុំចុះបញ្ជីបេក្ខជន (ទ.១០០៨) ទាំង ០២ (ពីរ) ច្បាប់ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា រួចជូនទៅសាមីគណបក្សនយោបាយ ០១ (មួយ)ច្បាប់ និងរក្សាទុក ០១ (មួយ)ច្បាប់ ។

៦.១៣.៣.៣ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេចយល់ព្រមពី គ.ជ.ប ។

៦.១៣.៣.៤ ប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ មានសិទ្ធិប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ ។ នីតិវិធីនៃការប្តឹងជំទាស់នឹងបេក្ខជន ឬបញ្ជីបេក្ខជនដំបូងត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៦.១៥ ។

៦.១៣.៣.៥ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៦.១៣.៣.៤ បើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងជំទាស់អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងទេនោះ ចាត់ទុកថាគ្មានការប្តឹងជំទាស់ ។ បញ្ជីបេក្ខជនដំបូងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការ ។ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជននីមួយៗ ក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ ។

៦.១៣.៣.៦ គឃ.សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជន ដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ គធ.ខប ។ ការចាប់ឆ្នោតកំណត់លេខរៀង គឃ.សប ត្រូវអនុវត្តដូចមានចែងក្រោមប្រការ ៦.២០ ។

៦.១៣.៤ ក្នុងករណីបដិសេធបណ្តឹងតវ៉ា គ.ជ.ប ត្រូវ ៖

- បំពេញសម្រង់សេចក្តីសម្រេចលើបណ្តឹងតវ៉ា (ទ.១២០៣) ចំនួន ០៤ (បួន) ច្បាប់ រួចផ្ញើជូន ៖
    - អ្នកប្តឹងតវ៉ា ០១ (មួយ) ច្បាប់
    - គធ.ខប ០១ (មួយ) ច្បាប់
    - គឃ.សប ០១ (មួយ) ច្បាប់
    - រក្សាទុកជាឯកសារ ០១ (មួយ) ច្បាប់
- ផ្តល់ដំណឹងដល់គណបក្សនយោបាយ ដែលដាក់ពាក្យបណ្តឹងតវ៉ា ឬតំណាងថាសេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ។

**ប្រការ ៦.១៤.-**

បន្ទាប់ពីបញ្ចប់រយៈពេលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ហើយឃុំ សង្កាត់ណាដែលការប្ដឹងតវ៉ាទាំងអស់ ត្រូវបានដោះស្រាយរួចរាល់ គ.ជ.ប ត្រូវចាត់ឱ្យ គឃ.សប បិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលសម្រង់សេចក្ដីសម្រេចពី គ.ជ.ប ។

**ប្រការ ៦.១៥.-**

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះមានសិទ្ធិប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅ គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូង ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយជាសាធារណៈ ។

៦.១៥.១ បណ្ដឹងជំទាស់ត្រូវចោទប្រកាន់ទៅលើបេក្ខជន ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ដែលបំពេញមិនបានគ្រប់គ្រាន់តាមលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ ៦.១ ៦.២ ៦.៣ ៦.៥ និង ៦.៦ នៃ ប.ន.ឃ.ស នេះ ។

៦.១៥.២ បណ្ដឹងជំទាស់ទាំងនោះត្រូវបង្ហាញអំពីបេក្ខជន ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយជាក់លាក់ណាមួយដោយបញ្ជាក់ពីចំណុចខ្វះខាតជាក់ស្ដែងរបស់បេក្ខជន ឬបញ្ជីបេក្ខជននោះ និងហេតុផលដែលស្នើសុំឱ្យច្រានចោលបេក្ខជន ឬបញ្ជីបេក្ខជននោះផង ។

**ប្រការ ៦.១៦.-**

គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្ដឹងជំទាស់ ។ គ.ជ.ប ត្រូវផ្ដល់ព័ត៌មានដល់គណបក្សនយោបាយ ដែលបានដាក់ស្នើបញ្ជីបេក្ខជនមានការប្ដឹងជំទាស់ ផ្ដល់ព័ត៌មានដល់អ្នកប្ដឹងជំទាស់ ឬតំណាង និងផ្សព្វផ្សាយជាសាធារណៈ អំពីកាលបរិច្ឆេទពេលវេលា និងទីកន្លែងដែលត្រូវបើកសវនាការនោះ ។

**ប្រការ ៦.១៧.-**

ក្នុងករណីយល់ព្រម ឬបដិសេធលើបណ្ដឹងជំទាស់ណាមួយ គ.ជ.ប ត្រូវ ៖

៦.១៧.១ បំពេញសម្រង់សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ (ទ.១២០៣) ជា ០៥ (ប្រាំ) ច្បាប់ រួចផ្ញើជូន ៖

- អ្នកប្ដឹងជំទាស់ ០១ (មួយ) ច្បាប់
- គណបក្សនយោបាយត្រូវគេប្ដឹងជំទាស់ ០១ (មួយ) ច្បាប់

- គធ.ខប ពាក់ព័ន្ធ 		០១ (មួយ) ច្បាប់
- គឃ.សប ពាក់ព័ន្ធ 		០១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ 		០១ (មួយ) ច្បាប់ ។

៦.១៧.២ ផ្តល់ដំណឹងដល់អ្នកប្តឹងជំទាស់ និងសាមីគណបក្សនយោបាយនៃបញ្ជីបេក្ខជននោះ ថា សេចក្តីសម្រេចរបស់ គ.ជ.ប ជាសេចក្តីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ។

**ប្រការ** ៦.១៨.-

ក្នុងករណីបណ្តឹងជំទាស់ត្រូវបានយល់ព្រមដោយ គ.ជ.ប តាមសម្រង់សេចក្តីសម្រេច ដូចក្នុង ចំណុច ៦.១៧.១ គឃ.សប ត្រូវបដិសេធបេក្ខភាព ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមាន ការប្តឹងជំទាស់នោះ រួចហើយលុបបេក្ខភាព ឬបញ្ជីបេក្ខជននោះចេញព្រមទាំងដកហូត និងបដិសេធលិខិត បញ្ជាក់ការចុះបញ្ជីបេក្ខជននោះ ។

៦.១៨.១ ក្នុងករណី គ.ជ.ប សម្រេចយល់ព្រមតាមបណ្តឹងជំទាស់ដោយលុបបេក្ខភាពបេក្ខជន នៃគណបក្សនយោបាយដែលមានការប្តឹងជំទាស់ គឃ.សប ត្រូវបដិសេធបេក្ខភាព ដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់នោះតែប៉ុណ្ណោះ ដោយរក្សាបញ្ជីបេក្ខជននោះ មានសុពលភាពដដែល ។ គឃ.សប ត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជី បេក្ខជន និងត្រូវចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយ ហើយចេញលិខិតបញ្ជាក់ ការចុះបញ្ជីបេក្ខជនជូនគណបក្សនយោបាយសាមី ។

៦.១៨.២ ក្នុងករណី គ.ជ.ប សម្រេចយល់ព្រមតាមបណ្តឹងជំទាស់ដោយលុបបញ្ជីបេក្ខជននៃ គណបក្សនយោបាយដែលមានការប្តឹងជំទាស់ គឃ.សប ត្រូវលុបបញ្ជីបេក្ខជននៃ គណបក្សនយោបាយនោះចេញ ព្រមទាំងដកហូត និងបដិសេធលិខិតបញ្ជាក់ការ ចុះបញ្ជីបេក្ខជននោះ ។

**ប្រការ** ៦.១៩.-

បញ្ជីបេក្ខជនដំបូង នឹងក្លាយទៅជាបញ្ជីបេក្ខជនផ្លូវការប្រសិនបើគ្មានបណ្តឹងជំទាស់មកលើបញ្ជីនេះ ក្នុងរយៈពេលដូចដែលបានកំណត់ក្នុងប្រការ ៦.១៤ ឬការប្តឹងជំទាស់ត្រូវបាន ដោះស្រាយស្របតាម លក្ខខណ្ឌដូចមានចែងក្នុងប្រការ ៦.១៥ ៦.១៦ ៦.១៧ និង ៦.១៨ នៃ ប.ន.ឃ.ស នេះ ។

**ការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត**

**ប្រការ** ៦.២០.-

គឃ.សប ត្រូវធ្វើការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត និងធ្វើសេចក្តីរាយការណ៍ជាបន្ទាន់អំពីលទ្ធផលនៃការចាប់ឆ្នោតនេះទៅ គ.ជ.ប តាមរយៈ គធ.ខប ។

៦.២០.១ ផ្អែកលើបញ្ជីបេក្ខជនផ្លូវការ គឃ.សប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត ។

៦.២០.២ ការចាប់ឆ្នោតត្រូវធ្វើឡើងជាសាធារណៈ ។ គឃ.សប ត្រូវបិទផ្សាយជាសាធារណៈ អំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលាយ៉ាងហោចណាស់ ២៤ (ម្ភៃបួន) ម៉ោង មុននឹងចាប់ផ្តើមធ្វើពិធីចាប់ឆ្នោត ។

៦.២០.៣ លិខិតអញ្ជើញត្រូវប្រគល់ជូនទៅគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់របស់ខ្លួន និងដែលមានចុះហត្ថលេខារបស់អ្នកទទួលសម្រាប់ទុកជាឯកសារយ៉ាងហោចណាស់ ២៤ (ម្ភៃបួន) ម៉ោង មុនពិធីចាប់ឆ្នោត ។

៦.២០.៤ របៀបវារៈនៃពិធីចាប់ឆ្នោតមានដូចខាងក្រោមនេះ ៖

- ៦.២០.៤.១ សុន្ទរកថាបើកពិធី ថ្លែងដោយប្រធាន គឃ.សប ។
- ៦.២០.៤.២ ការបង្ហាញសន្លឹកឆ្នោតសម្រាប់ចាប់ឆ្នោត និងស្រោមសំបុត្រ។
- ៦.២០.៤.៣ ការចាប់ឆ្នោតត្រូវធ្វើដោយព្រះសង្ឃ ឬឥស្សរជនចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យដែលមានជំហរអព្យាក្រឹត និងដែលអាចទទួលយកបានពីគ្រប់គណបក្សនយោបាយ ។
- ៦.២០.៤.៤ ការប្រកាសលទ្ធផលនៃការចាប់ឆ្នោត ។
- ៦.២០.៤.៥ ការបិទពិធីចាប់ឆ្នោត ។

៦.២០.៥ គឃ.សប ត្រូវរៀបចំក្រដាសសមួយសន្លឹកសម្រាប់គណបក្សនយោបាយនីមួយៗ ។

- ៦.២០.៥.១ ក្រដាសនេះមានប្រភេទដូចគ្នា និងទំហំប៉ុនគ្នា ។

៦.២០.៥.២ ត្រូវសរសេរឈ្មោះគណបក្សជាអក្សរដែលមានពណ៌ និងប្រភេទតួអក្សរដូចគ្នា និងមានទំហំប៉ុនគ្នា នៅលើក្រដាសសនេះ ។

៦.២០.៥.៣ ក្រដាសដែលបានសរសេរឈ្មោះគណបក្សនយោបាយនីមួយៗរួចហើយ ត្រូវក្លាយទៅជាសន្លឹកឆ្នោតរបស់គណបក្ស ដែលនឹងត្រូវបត់ដាក់ចូលក្នុងស្រោមសំបុត្រ ដែលមានទំហំប៉ុនគ្នា ពណ៌ដូចគ្នា រួចមូរនិងចងកៅស៊ូកងពណ៌ដូចគ្នា ។

៦.២០.៦ មុនចាប់ផ្តើមការចាប់ឆ្នោត គឃ.សប ត្រូវបង្ហាញសន្លឹកឆ្នោតរបស់គណបក្សនីមួយៗ នៅចំពោះមុខអង្គពិធីមុននឹងបត់ដាក់ចូល និងបិទភ្ជិតស្រោមសំបុត្រ ។

៦.២០.៦.១ សន្លឹកឆ្នោតនីមួយៗ ត្រូវបត់ជា ០២ (ពីរ) ផ្នត់ ហើយស៊កបញ្ចូលក្នុងស្រោមសំបុត្ររួចបិទភ្ជិត ។

៦.២០.៦.២ ស្រោមសំបុត្រឆ្នោតទាំងអស់ ត្រូវដាក់ច្របល់បញ្ចូលគ្នាក្នុងប្រអប់ ឬឡាំងតែមួយ ហើយត្រូវក្រឡុកប្រអប់ ឬឡាំងឆ្នោតនោះ ។

៦.២០.៦.៣ បន្ទាប់មកត្រូវនិមន្តព្រះសង្ឃ ឬអញ្ជើញឥស្សរជនចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យ ដែលត្រូវបានជ្រើសរើសហើយតាមលក្ខខណ្ឌ ដូចចំណុច ៦.២០.៤.៣ ចាប់យកស្រោមសំបុត្រឆ្នោតម្តងមួយៗ ពីប្រអប់ ឬឡាំងឆ្នោត ។

៦.២០.៦.៤ ស្រោមសំបុត្រឆ្នោត ដែលចាប់បានត្រូវប្រគល់ទៅមន្ត្រីបោះឆ្នោតម្នាក់ក្នុងចំណោម ០២ (ពីរ) នាក់ ដែលជាសមាជិក គឃ.សប ។

៦.២០.៦.៥ មន្ត្រី គឃ.សប ០១ (មួយ) នាក់ ត្រូវបើកស្រោមសំបុត្របង្ហាញសន្លឹកឆ្នោតរបស់គណបក្សនៅចំពោះមុខអង្គពិធី ហើយជូនសន្លឹកឆ្នោតនោះទៅឱ្យមន្ត្រីទីពីរ ។

៦.២០.៦.៦ មន្ត្រីទីពីរត្រូវអានឈ្មោះគណបក្សនយោបាយ ដែលសរសេរនៅលើសន្លឹកឆ្នោតឱ្យបានឮ និងសរសេរលេខរៀង " លេខ ១ " នៅលើសន្លឹកឆ្នោតនោះ ហើយត្រូវបន្តធ្វើការចាប់ឆ្នោត និងចុះលេខរៀងតាមលំដាប់រហូតដល់សន្លឹកឆ្នោតចុងក្រោយបង្អស់ ។

៦.២០.៧ លេខាធិការនៃ គឃ.សប ត្រូវធានាបំពេញកំណត់ហេតុនៃការចាប់ឆ្នោតកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត (ទ.១១២១)

ឱ្យបានរួចរាល់ ដោយត្រូវដាក់ភ្ជាប់ជាមួយនូវសន្លឹកឆ្នោតរបស់គណបក្ស ដែលបានចុះលេខរៀងហើយ ដូចមានចែងក្នុងចំណុច ៦.២០.៦.៦ ។ តំណាងគណបក្សនយោបាយអាចចូលរួម ចុះហត្ថលេខានៅលើកំណត់ហេតុនេះបាន ។

៦.២០.៨ គយ.សប ត្រូវធ្វើបញ្ជីកំណត់លេខរៀងបញ្ជីបេក្ខជន ដែលត្រូវដាក់លើសន្លឹកឆ្នោតតាមលទ្ធផលនៃការចាប់ឆ្នោតជា០៤ (បួន) ច្បាប់ ដើម្បីផ្ញើជូន ៖

- គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ០១ (មួយ) ច្បាប់
- គធ.ខប ០១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ០១ (មួយ) ច្បាប់
- បិទផ្សាយ ០១ (មួយ) ច្បាប់

គយ.សប ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ អំពីលទ្ធផលនៃការចាប់ឆ្នោតនេះ ដោយភ្ជាប់ជាមួយនូវកំណត់ហេតុ ដូចចែងក្នុងចំណុច ៦.២០.៧ ដើម្បីផ្ញើជូនទៅ គ.ជ.ប តាមរយៈ គធ.ខប ។

៦.២០.៩ គ.ជ.ប ត្រូវធ្វើគំរូ និងបោះពុម្ពសន្លឹកឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ ។

៦.២០.៩.១ ការបោះពុម្ពសន្លឹកឆ្នោត ត្រូវផ្អែកតាមចំនួនគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនផ្លូវការនៅក្នុងឃុំ សង្កាត់នោះ ។ សន្លឹកឆ្នោតសម្រាប់ឃុំ សង្កាត់ណាប្រើប្រាស់បានតែនៅមណ្ឌលឃុំ សង្កាត់នោះតែប៉ុណ្ណោះ ។

៦.២០.៩.២ ឈ្មោះ រូបសញ្ញាគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ត្រូវបោះពុម្ពតាមរបៀបតែមួយគត់ ហើយលេខសម្គាល់របស់គណបក្សនយោបាយត្រូវដាក់ជាលេខរៀងតាមលទ្ធផលនៃការចាប់ឆ្នោត ។

**ប្រការ** ៦.២១._

គយ.សប ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជនផ្លូវការ និងឈ្មោះបេក្ខជនក្នុងបញ្ជីនីមួយៗ ក្នុងរយៈពេលយ៉ាងយូរប្រាំ ០៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីបញ្ជីបេក្ខជនដំបូងក្លាយជាបញ្ជីបេក្ខជនផ្លូវការ ។ បញ្ជីបេក្ខជនផ្លូវការ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជន នៅក្នុងបញ្ជីមិនអាចកែប្រែបានឡើយ ។

**ប្រការ** ៦.២២.-

គ.ជ.ប ត្រូវរៀបចំបញ្ជីបេក្ខជនផ្លូវការតាមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត នៅតាមឃុំសង្កាត់នីមួយៗ ។

៦.២២.១ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវបញ្ចូល និងគ្រប់គ្រងទិន្នន័យបញ្ជីបេក្ខជនផ្លូវការ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធដើម្បីប្រគល់ទិន្នន័យនេះសម្រាប់បម្រើឱ្យការប្រកាសលទ្ធផលនៃការបោះឆ្នោត ។

៦.២២.២ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងរាយការណ៍ជូន គ.ជ.ប ដើម្បីពិនិត្យសម្រេច។

**ប្រការ** ៦.២៣.-

គណបក្សនយោបាយ និងបេក្ខជននៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីជាផ្លូវការត្រូវគោរព ច.ប.ឃ.ស ប.ន.ឃ.ស និងក្រមសីលធម៌ ដែលកំណត់ដោយ គ.ជ.ប ។